# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៙៚៙

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ រវាង

**លោក អ៊ី សុគន្ធរតន៍** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៧៩១៦១០ ដែលមានតួនាទី **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **ហ្វីដឡាយហ្វ៍ ៦.ក** ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ២៥ ផ្លូវ៥២៨ កែងផ្លូវ២៨៣ សង្កាត់បឹងកក់១ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

និង

**លោកស្រី ឡើន សុនែត** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៨០៦៦៥៥៧៣ ដែលមានតួនាទីជា **ប្រធានផ្នែកគ្រប់គ្រងរោងនីយដ្ឋាន** និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។

**លោក ខួន ប៊ុននី** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១២៦៧៩៨៣ ដែលមានតួនាទីជា **មេផ្នែកចុងភៅ** និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

## ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**០១- រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

**០២- ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

**០៣- កាលបរិច្ឆេទចូលបម្រើការងារវិញ៖**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០

| **តំណាងភាគីនិយោជិត** | | **តំណាងភាគីនិយោជក** |
|---|---|---|
| **លោកស្រី ឡើន សុនែត** | **លោក ខួន ប៊ុននី** | **លោក អ៊ី សុគន្ធរតន៍** |